គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
The National Committee for Sub-National Democratic Development

# សិក្ខាសាលាជាតិ

## ស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០២០ របស់ គ.ជ.អ.ប.

# របាយការណ៍សង្ខេបអំពីវឌ្ឍនភាព នៃការអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០១៩ របស់ គ.ជ.អ.ប.

រាជធានីភ្នំពេញ សាលប្រជុំក្រសួងមហាផ្ទៃ ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩

# មាតិកា

I. សេចក្តីសង្ខេបផែនការសកម្មភាព និងថវិកាឆ្នាំ២០១៩

II. ខ្លឹមសារនៃរបាយការណ៍

# I. សេចក្តីសង្ខេបផែនការសកម្មភាព និងថវិកាឆ្នាំ២០១៩

- ផ.ស.ថ ២០១៩ ត្រូវបានអនុម័តដោយ គ.ជ.អ.ប. (០៨ កុម្ភៈ ២០១៩)
- ផ.ស.ថ ២០១៩ ផ្អែកលើសមាសភាគទាំង៥ នៃកម្មវិធីជាតិ១០ឆ្នាំ (១.ការងារគ្រប់គ្រងការងារកំណែទម្រង់ ២.អភិបាលកិច្ចល្អ ៣.ការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្ស ៤.ការផ្តល់សេវានិងការអភិវឌ្ឍមូលដ្ឋាន និង៥.វិមជ្ឈការហិរញ្ញវត្ថុ)
- សកម្មភាពសរុបមានចំនួន៩១ ក្នុងនោះ៖
  - ✓ សកម្មភាពជាអាទិភាពចំនួន៣៩
  - ✓ សកម្មភាពដែលមានលក្ខណៈគាំទ្រចំនួន៥២
- ថវិកាសរុបមានចំនួនប្រមាណ២.៣៨០ ប៊ីលានរៀល (៥៩៥លានដុល្លារ) ក្នុងនោះ ៖
  - ✓ រាជរដ្ឋាភិបាល ២.២១០ ប៊ីលានរៀល (៥៥២ លានដុល្លារ)
  - ✓ ថវិកាកម្ចីពីដៃគូអភិវឌ្ឍ ៧៦,៤ ប៊ីលានរៀល (១៩ លានដុល្លារ)
  - ✓ ជំនួយឥតសំណងរបស់ដៃគូអភិវឌ្ឍ ៩៥,១ ប៊ីលានរៀល (២៤ លានដុល្លារ)

# II. ខ្លឹមសារនៃរបាយការណ៍

- គ្រប់ដណ្តប់រយៈពេល **១១ខែ** ពីខែមករា ដល់ខែវិច្ឆិកា ឆ្នាំ២០១៩
- ខ្លឹមសារសំខាន់ៗរួមមាន៖

  ១. វឌ្ឍនភាព

  ២. ស្ថានភាពហិរញ្ញវត្ថុ

  ៣. បញ្ហាប្រឈម និងសំណើដំណោះស្រាយ

# ១. អំពីវឌ្ឍនភាព

- ផ្ដោតជាសំខាន់ទៅលើការអនុវត្តសកម្មភាពជាអាទិភាពទាំង៣៩ ដោយពុំផ្ដោតទៅលើសកម្មភាពដែលមានលក្ខណៈគាំទ្រការងារប្រចាំថ្ងៃនោះឡើយ
- **ក្នុងចំណោមសកម្មភាពជាអាទិភាពទាំង ៣៩** នេះ រួមមានសកម្មភាពជាអាទិភាពចំនួន ៣៨ បានអនុវត្តដែលក្នុងនោះ ៖
  - ✓ សកម្មភាពចំនួន ១៣ បានអនុវត្តចប់១០០%
  - ✓ សកម្មភាពចំនួន ២៥ កំពុងបន្តអនុវត្ត
- សកម្មភាពជាអាទិភាពចំនួន១ មិនទាន់បានអនុវត្តដែលពាក់ព័ន្ធនឹងការពិនិត្យ និងការកែសម្រួលផែនការយុទ្ធសាស្ត្រ ស្ដីពីអធិការកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

# ១. អំពីវឌ្ឍនភាព (ត)



45
40
35
30
25
20
15
10
5
0
ផែនការ
វឌ្ឍនភាព
បញ្ចប់១០០%
8 8 5
6 5 2
4 4 1
17 17 3
4 4 2
39 38 13
ការគ្រប់គ្រងការងារកំណែទម្រង់
អភិបាលកិច្ចល្អ
ការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស
ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន
វិមជ្ឈការហិរញ្ញវត្ថុ
សរុប

# ១. អំពីវឌ្ឍនភាព (ត)

1. ការពិនិត្យ និងសម្រួលរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ ៖
   - ✓ បានអនុម័តអនុក្រឹត្យស្តីពីមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង
   - ✓ បានអនុម័តអនុក្រឹត្យស្តីពីមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលស្រុក
   - ✓ បានអនុម័តអនុក្រឹត្យស្តីពីមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលខណ្ឌ


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
រាជរដ្ឋាភិបាលកម្ពុជា
អនុក្រឹត្យ
ស្តីពី
មុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង
រាជរដ្ឋាភិបាល

# ១. អំពីវឌ្ឍនភាព (ត)

2. ការពិនិត្យ និងការកែសម្រួលរចនាសម្ព័ន្ធលេខាធិការដ្ឋាន គ.ជ.អ.ប. ៖

- ✓ បានបង្កើតគណៈកម្មការគ្រប់គ្រងមូលនិធិផ្អែកលើលទ្ធផលការងារ
- ✓ បានរៀបចំសេចក្តីព្រាងសេចក្តីសម្រេចបង្កើតគណៈកម្មការត្រួតពិនិត្យលើការអនុវត្តកម្មវិធី
- ✓ បានរៀបចំសេចក្តីព្រាងសេចក្តីសម្រេចបង្កើតគណៈកម្មការសវនកម្មផ្ទៃក្នុង និងក្រមសីលធម៌



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
លេខាធិការដ្ឋាន

លេខ: ០០៩សស.ន/គ.ជ.អ.ប

ថ្ងៃ.................. ខែ.................. ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី...២៦...... ខែ...កក្កដា... ឆ្នាំ២០១៩

**សេចក្តីសម្រេច**
**ស្តីពីការបង្កើតគណៈកម្មាធិការផ្តល់មូលនិធិ**
**នៃមូលនិធិផ្អែកលើលទ្ធផលនៃការអនុវត្តសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំង

**ប្រការ៦ ÷** ប្រធាន និងសមាជិកនៃគណៈកម្មាធិការមូលនិធិដូចមានចែងក្នុងប្រការ២ និងអង្គភាពចំណុះនៃលេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវអនុវត្តនូវសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**

ង៉ាន់ ចំរើន

# ១. អំពីវឌ្ឍនភាព (ត)

3. សកម្មភាពកំណែទម្រង់ស្នូលនានានៃផអពទី៣ ត្រូវបានរៀបចំបញ្ចូល និងគាំទ្រដោយថវិការបស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ៖
   - ✓ ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌបានគ្រោង និងប្រើប្រាស់ថវិការបស់ខ្លួនក្នុងការអនុវត្តសកម្មភាពពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សេចក្តីសម្រេចរួម

រវាង

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.)

និង

ស្ថាប័នអនុវត្ត ៖ ក្រសួងសាធារណការ និងដឹកជញ្ជូន

ស្តីពី

ការអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០១៩

សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

លេខកូដ ៖ 57/MPWT/1901-00 (IP3-III)



ប្រការ ១៣.-

អ្នកចុះហត្ថលេខាខាងក្រោមនេះ គឺជាតំណាងពេញសិទ្ធិរបស់ គ.ជ.អ.ប. និងស្ថាប័នអនុវត្តបានព្រមព្រៀងទៅលើលក្ខខណ្ឌនានា ដែលមានចែងក្នុងសេចក្តីសម្រេចរួមនេះ។

| តំណាង គ.ជ.អ.ប. | តំណាងស្ថាប័នអនុវត្ត |
|---|---|
| ឈ្មោះ ៖ ង៉ាន់ ចំរើន | ឈ្មោះ ៖ ស៊ុន ចាន់ថុល |
| មុខតំណែង ៖ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប. | មុខតំណែង ៖ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន |
| កាលបរិច្ឆេទ ៖ | កាលបរិច្ឆេទ ៖ |



តារាង ផ.ស.ផ. ឆ្នាំ២០១៩

ក្រសួង ស្ថាប័ន ៖ ក្រសួងសាធារណការ និងដឹកជញ្ជូន

# ១. អំពីវឌ្ឍនភាព (ត)

4. ការប្រាស្រ័យទាក់ទង និងការផ្សព្វផ្សាយព័ត៌មាន ដើម្បីលើកកម្ពស់ចំណេះដឹង និងការយល់ដឹងអំពីវិមជ្ឈការ និងវិសហមជ្ឈការ ៖
   - ✓ បានរៀបចំ និងផ្សព្វផ្សាយព័ត៌មានតាមមធ្យោបាយដូចខាងក្រោម ៖
     - ព្រឹត្តិការណ៍ព័ត៌មានចំនួន ២៦៩
     - អត្ថបទបទយកការណ៍ចំនួន ៦
     - អត្ថបទព័ត៌មាន រូបថត និងវីដេអូខ្លីៗ ចំនួន ៥








# ១. អំពីវឌ្ឍនភាព (ត)

5. ការអនុវត្តយុទ្ធសាស្ត្រត្រួតពិនិត្យ វាយតម្លៃ និងក្របខ័ណ្ឌនៃកម្មវិធី ត្រូវបានរៀបចំ និងអនុម័ត រួមមាន៖
   - ✓ សៀវភៅណែនាំស្តីពីការត្រួតពិនិត្យ និងការវាយតម្លៃរបស់ គ.ជ.អ.ប. ត្រូវបានអនុម័ត ដោយ គ.ជ.អ.ប.
   - ✓ ក្របខ័ណ្ឌនៃកម្មវិធីត្រូវបានអនុម័ត



# ១. អំពីវឌ្ឍនភាព (ត)

6. ការងារគណនេយ្យភាពសង្គមត្រូវបានពង្រីក និងអនុវត្តក្នុងក្រុង ស្រុក ខណ្ឌគោលដៅចំនួន១២៣ នៃរាជធានី ខេត្តចំនួន២១ ៖
   - ✓ ក្រុង ស្រុក ខណ្ឌគោលដៅចំនួន១២៣ ត្រូវបានដាក់ឱ្យអនុវត្តការងារគណនេយ្យភាពសង្គម ដោយមានការបន្តគាំទ្រពីលេខាធិការដ្ឋាន គ.ជ.អ.ប. និងរដ្ឋបាលរាជធានី ខេត្តសាមីទាំង២១
     - រដ្ឋបាលឃុំ សង្កាត់ចំនួន១០៧៨
     - សាលាបឋមសិក្សាចំនួន៥១០៧
     - មណ្ឌលសុខភាពចំនួន៨២២










# ១. អំពីវឌ្ឍនភាព (ត)

7. យន្តការសម្រុះសម្រួលដោះស្រាយបណ្តឹងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានបង្កើតនិងដំណើរការ ៖

- ✓ ការិ.ប្រជាពលរដ្ឋនៅថ្នាក់រាជធានី ខេត្តទាំង២៥ត្រូវបានបង្កើត និងដំណើរការ
- ✓ ការិ.ប្រជាពលរដ្ឋនៅថ្នាក់ក្រុង ស្រុក ខណ្ឌថ្មីចំនួន**៣២** ត្រូវបានដាក់ឱ្យដំណើរការ
- ✓ បានបណ្តុះបណ្តាលចំនួន**៥វ**គ្គ (អ្នកចូលរួមចំនួន**១៨៨**)
- ✓ បានទទួលបណ្តឹង**សរុប៥០១**ករណី៖
    - **២២៣**ករណីជាបណ្តឹងក្នុងសមត្ថកិច្ច(**២០១** ត្រូវបានដោះស្រាយរួចរាល់)
    - **២៧៨**ករណីជាបណ្តឹងក្រៅសមត្ថកិច្ច



# ១. អំពីវឌ្ឍនភាព (ត)

8. ការអភិវឌ្ឍសមត្ថភាពដោយសាលាជាតិរដ្ឋបាលមូលដ្ឋាន៖

- ✓ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីអំពីភាពជាអ្នកដឹកនាំចំនួន២វគ្គសម្រាប់អភិបាល អភិបាលរងក្រុង ស្រុក ខណ្ឌជាស្ត្រី សរុបចំនួន ៦០នាក់
- ✓ បានរៀបចំវគ្គវិក្រឹត្យការមូលដ្ឋានមន្ត្រីរដ្ឋបាលក្រុង ស្រុក ខណ្ឌចំនួន ៣០នាក់






# ១. អំពីវឌ្ឍនភាព (ត)

9. ការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ៖
   - ✓ ការផ្ទេរមុខងារក្នុងវិស័យផ្សេងៗទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ (១៨វិស័យ ៥៥មុខងារ )



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៨៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
មុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង

រាជរដ្ឋាភិបាល



ឧបសម្ព័ន្ធទី១៖ បញ្ជីមុខងាររបស់រដ្ឋបាលស្រុក
ភ្ជាប់នឹងអនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃទី ២ ខែ ... ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលស្រុក

| មុខងារ | មុខងាររង/សកម្មភាព |
|---|---|
| I. មុខងារដែលត្រូវបានប្រគល់ | |
| ក. វិស័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល | |
| ១. ការងាររៀបចំដែនដី និងនគរូបនីយកម្ម | ១. ការរៀបចំប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក ប្លង់គោលប្រើប្រាស់ដីទីប្រជុំជន ផែនការប្រើប្រាស់ដីទីប្រជុំជន និងប្លង់លម្អិត នគរូបនីយកម្មនៃតំបន់ណាមួយនៅក្នុងស្រុក។ |
| ២. ការងារភូមិបាល | ១. ការផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុដែលមិនទាន់ចុះបញ្ជី<br>២. កិច្ចការពារដីសាធារណៈ និងដីឯកជនរបស់រដ្ឋ ដោយចាត់វិធានការទប់ស្កាត់ការបំពាន ឬការចូលទន្ទ្រានកាន់កាប់ដីរដ្ឋ។ |
| ៣. ការងារសំណង់ | ១. ការផ្តល់លិខិតអនុញ្ញាតសាងសង់ ជួសជុល រុះរើ ឬបើកការដ្ឋាន និងផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ ចំពោះបណ្តាសំណង់លំនៅឋានដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបមិនលើសពី ៥០០ ម៉ែត្រក្រឡា និងមានកម្ពស់មិនលើសពី ៤ ជាន់ រួមទាំងជាន់ផ្ទាល់ដី (Eo E1 E2 E3)<br>២. លិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ របងដែលមានកម្ពស់មិនលើសពី៣ម៉ែត្រគិតពីកម្រិតកម្ពស់ដីនៅជើងរបង<br>៣. ការបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់ រុះរើ ជួសជុល លិខិតអនុញ្ញាតបើកការដ្ឋាន និងវិញ្ញាបនបត្រប្រើប្រាស់សំណង់ សម្រាប់សំណង់មានផ្ទៃក្រឡាមិនលើសពី៥០០ ម៉ែត្រក្រឡា និងមានកម្ពស់មិនលើសពី៤ ជាន់ រួមទាំងជាន់ផ្ទាល់ដី (Eo E1 E2 E3)<br>៤. លិខិតផ្អាកការសាងសង់ចំពោះរាល់សកម្មភាពសាងសង់ដែលមិនគោរពតាមបទប្បញ្ញត្តិជាធរមាន។ |
| ៤. ការងារលំនៅឋាន | ១. ពិនិត្យផ្តល់យោបល់លើផែនការសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន<br>២. ការបង្ការ និងទប់ស្កាត់សំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់នៅក្នុងស្រុក។ |

៧/៣០

# ១. អំពីវឌ្ឍនភាព (ត)

10. ការផ្ទេរមុខងារវិស័យសុខាភិបាលទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ៖

- ✓ ការផ្ទេរមុខងារក្នុងវិស័យសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត (មុខងារគ្រប់គ្រងមន្ទីរសុខាភិបាល ការិ.សុខាភិបាលស្រុកប្រតិបត្តិ និងការផ្តល់សេវាសុខាភិបាលនៃមន្ទីរពេទ្យបង្អែករាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព)



អនុក្រឹត្យ

ស្តីពី

ការប្រគល់មុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាល

ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

# ១. អំពីវឌ្ឍនភាព (ត)

11. បានពង្រឹង និងពង្រីកការិ. ច្រកចេញចូលតែមួយនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ (១១៥) ៖
    - ✓ បានដាក់ឱ្យដំណើរការនៅស្រុកចំនួន៣១
    - ✓ បានកំណត់ក្រុង ស្រុក ខណ្ឌថ្មីចំនួន៣២
    - ✓ បានផ្តល់វគ្គបណ្តុះបណ្តាលចំនួន១០វគ្គ មានសិក្ខាកាមចំនួន១៨០០
    - ✓ បានផ្តល់សេវាចំនួន៩៣៤,៨៤៩សេវា ចំណូល ៤.២លានដុល្លារ (ក្រុងស្រុកខណ្ឌ)
    - ✓ បានផ្តល់សេវាចំនួន៤៥២,៩៧៤សេវា ចំណូល ១០លានដុល្លារ (រាជធានីខេត្ត)


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ:២៩៤៧ ឥ.ស.ស

សេចក្តីសម្រេច
ស្តីពី
ការកំណត់ស្រុកគោលដៅសម្រាប់បង្កើតការិយាល័យច្រកចេញចូលតែមួយ

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា


ថ្ងៃ.......ខែ.......ឆ្នាំ.......ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី.......ខែ.......ឆ្នាំ២០១៩
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្តេចក្រឡាហោម ស ខេង

# ១. អំពីវឌ្ឍនភាព (ត)

12. ការបង្កើនមូលនិធិឃុំ សង្កាត់ផ្នែកអភិវឌ្ឍន៍មូលដ្ឋាន ៖

- ✓ អនុក្រឹត្យស្ដីពីការផ្ទេរធនធានបន្ថែមពីថវិការដ្ឋជូនឃុំ សង្កាត់សម្រាប់ការចំណាយផ្នែកអភិវឌ្ឍន៍មូលដ្ឋាន(អត្រា១%)សម្រាប់ថិរវេលា៤ឆ្នាំ (២០២០-២០២៣) ត្រូវបានអនុម័តថ្ងៃទី២១ សីហា ២០១៩
- ✓ បានបង្កើនអត្រាចែករំលែកចំណូលពីពន្ធរបស់រដ្ឋបាលរាជធានី ខេត្តទៅឱ្យរដ្ឋបាលឃុំ សង្កាត់ (បង្កើនពី១%ឆ្នាំ២០១៩ ដល់៤%នៅឆ្នាំ ២០២០ និងកើន០.៥%ជារៀងរាល់ឆ្នាំដល់ឆ្នាំ ២០២៤)



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :១២១ អនក្រ.បក

អនុក្រឹត្យ
ស្ដីពី
ការផ្ទេរធនធានបន្ថែមពីថវិការដ្ឋជូនរដ្ឋបាលឃុំ សង្កាត់
សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការ



អនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៩

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្ដីជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្ដេចក្រឡាហោម ស ខេង

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

# ១. អំពីវឌ្ឍនភាព (ត)

13. ការផ្ដល់មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ (SNIF) ដើម្បីគាំទ្រគម្រោងនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ៖

- ✓ រដ្ឋបាលស្រុកគោលដៅចំនួន១៥នៃខេត្តចំនួន៩ ត្រូវបានបញ្ចប់ការវាយតម្លៃបឋម ដើម្បីទទួលមូលនិធិSNIF ដែលមានថវិកាសរុបចំនួន៦.០០០លានរៀល
- ✓ បានទូទាត់ថវិកាជូនស្រុកគោលដៅ (ឆ្នាំ២០១៨) ចំនួន២៥**គម្រោង (៧.០០០លានរៀល)** និងគ្រោងទូទាត់ជូនស្រុកគោលដៅចំនួន៩គម្រោងទៀត (២.៨៤៨លានរៀល)



# ២. ស្ថានភាពហិរញ្ញវត្ថុ

- របាយការណ៍ចំណាយនេះគ្រប់ដណ្តប់លើថវិកាដែលបានគ្រោងសម្រាប់៖
  - ✓ កិច្ចប្រតិបត្តិការរបស់លេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួងស្ថាប័ន និងរាជធានី ខេត្តដែលបានធ្វើសេចក្តីសម្រេចរួមជាមួយ គ.ជ.អ.ប.( តារាងទី១ )
  - ✓ ថវិការបស់គម្រោងដាច់ដោយឡែករបស់ដៃគូអភិវឌ្ឍមួយចំនួន ដែលស្ថិតក្រោមការសម្របសម្រួលរបស់លេខាធិការដ្ឋាន គ.ជ.អ.ប.( តារាងទី២ )

(មិនរៀបរាប់អំពីការវិភាជន៍ថវិការបស់រដ្ឋទៅរដ្ឋបាលថ្នាក់ក្រោមជាតិនោះឡើយ)

# ២. ស្ថានភាពហិរញ្ញវត្ថុ

## តារាងទី១ (គិតជាលានរៀល)

| ស្ថាប័ន | ថវិកាសរុប | ចំណាយ | សមតុល្យ |
|---|---|---|---|
| លេខាធិការដ្ឋាន គ.ជ.អ.ប. | 9.500 | 3.913 | **5.587** |
| ក្រសួង ស្ថាប័ននានា | 4.049 | 1.018 | **3.032** |
| រដ្ឋបាលថ្នាក់ក្រោមជាតិ | 19.045 | 1.668 | **17.377** |
| សរុប | **32.595** | **6.598** | **25.996** |



# ២. ស្ថានភាពហិរញ្ញវត្ថុ (ត)

## តារាងទី២ (គិតជាលានរៀល)

| ប្រភេទថវិកា | ថវិកា | ចំណាយ | សមតុល្យ |
|---|---|---|---|
| ថវិកាផ្ទេរទៅ SNAs | 79.890 | 23.612 | 56.278 |
| កំណែទម្រង់ស្នូល | 51.107 | 20.304 | 30.803 |
| សរុប | **130.997** | **43.916** | **87.081** |



# ៣. បញ្ហាប្រឈម និងសំណើដំណោះស្រាយ

| បញ្ហាប្រឈម | សំណើដោះស្រាយ |
|---|---|
| ▪ ភាពយឺតយ៉ាវនៃការរៀបចំ និងអនុវត្តសេចក្តីសម្រេចរួមរវាង គ.ជ.អ.ប. និងស្ថាប័ន អនុវត្តសម្រាប់អនុវត្ត ផ.ស.ថ. ឆ្នាំ២០១៩ ដែលនាំឱ្យមានយឺតយ៉ាវក្នុងការចាប់ផ្តើមអនុវត្តសកម្មភាព | ▪ ជំរុញការរៀបចំ និងការចុះហត្ថលេខាលើសេចក្តីសម្រេចរួមនានាឱ្យបានពីដើមឆ្នាំ |
| ▪ ភាពយឺតយ៉ាវនៃការរៀបចំ និងភាពទន់ខ្សោយនៃយន្តការដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (គ.ជ.វ.វ. )នៅតាមក្រសួង និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលធ្វើឱ្យមានភាពចន្លោះប្រហោងក្នុងការដឹកនាំការងារកំណែទម្រង់តាមស្ថាប័នសាមីនីមួយៗ | ▪ ពន្លឿនការរៀបចំ និងបន្តពង្រឹងការបំពេញតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ គ.ជ.វ.វ. នៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ |

# ៣. បញ្ហាប្រឈម និងសំណើដំណោះស្រាយ (ត)

| បញ្ហាប្រឈម | សំណើដោះស្រាយ |
|---|---|
| ▪ យន្តការនៃមូលនិធិកញ្ចប់រួម(Trust Fund) សម្រាប់ការគាំទ្រការងារគណនេយ្យភាពសង្គមពុំទាន់មានភាពច្បាស់ និងខ្វះថវិកាសម្រាប់អនុវត្តសកម្មភាពគណនេយ្យភាពសង្គមនៅថ្នាក់ក្រុង ស្រុក | ▪ បន្តការសម្របសម្រួល និងពិភាក្សាជាមួយធនាគារពិភពលោកដែលជាអ្នកគ្រប់គ្រងថវិកាកញ្ចប់រួមនេះ និងដៃគូអភិវឌ្ឍពាក់ព័ន្ធនានាដើម្បីអាចមានលទ្ធភាពប្រើប្រាស់ថវិកានេះឱ្យបានឆាប់បំផុត |
| ▪ ភាពយឺតយ៉ាវក្នុងការស្វែងរកការឯកភាពគ្នាលើបញ្ជីមុខងារតាមវិស័យមួយចំនួន ដែលត្រូវផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងការត្រៀមរៀបចំអនុវត្តអនុក្រឹត្យក្រុង ស្រុក ខណ្ឌ។ | ▪ បន្តកិច្ចសហការ និងសម្របសម្រួលជាមួយក្រសួង ស្ថាប័ននានាក្នុងការរៀបចំ និងអនុវត្តលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងការផ្ទេរមុខងារ និងការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងថ្មីរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ |

# សូមអរគុណ